# Akatsuki

## Ecommerce Solution in Cambodia

ការណែនាំអំពីសេវាកម្មរបស់ក្រុមហ៊ុនAkatsuki

Akatsuki

# មាតិកា៖

## 01. ការវិនិយោគនិងបេសកម្មរបស់យើងនៅក្នុងប្រទេសកម្ពុជា
កត្តាជុំរុញអោយធ្វើការវិនិយោគនិងបេសកម្មរបស់ក្រុមហ៊ុនAkatsukiនៅប្រទេសកម្ពុជា

## 02. ការណែនាំអំពីសេវាកម្មរបស់ក្រុមហ៊ុន
សេវាកម្មដែលក្រុមហ៊ុនAkatsukiផ្តល់ជូន

## 03. សមិទ្ធិផលរបស់ក្រុមហ៊ុន
សមិទ្ធិផលក្រុមហ៊ុនAkatsukiសំរេចបាន

## 04. ពត៏មានអំពីក្រុមហ៊ុន
អំពីក្រុមហ៊ុនរបស់យើង



# The Right Time For Smart Investments in Cambodia

ប្រទេសកម្ពុជាបាននិងកំពុងទាក់ទាញការវិនិយោគយ៉ាងសកម្មក្រោមគំនិតផ្ដួចផ្ដើមរបស់រដ្ឋាភិបាល ចាប់តាំងពីទសវត្សរ៍ឆ្នាំ 2000 រហូតមកដល់មុនកើតមានជំងឺរាតត្បាតសកល កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ច ក្នុងអត្រា 5.6% ជារៀងរាល់ឆ្នាំ។ ចំនុចពិសេសមួយក្នុងផែនការទាក់ទាញការវិនិយោគនេះគឺការបន្ធូរបន្ថយលើវិធានការហិរញ្ញវត្ថុដើម្បីសម្រួលដល់ការដាក់ទុនវិយោគពីបរទេស ចំនុចនេះហើយដែលក្រុមហ៊ុនAkatsuki បានប្រើប្រាស់សំរាប់វិនិយោគនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្ដល់ដំណោះស្រាយបច្ចេកវិទ្យាសម្រាប់អាជីវកម្មឆ្លងដែននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

**For More Information**

https://www.linkedin.com/pulse/right-time-smart-investments-cambodia-mal[illegible]comk/

https://it[illegible]ycambodia.com/blog/business-news/10-reasons-to-invest-in-cambodia/

Akatsuki

## ជាភ្នាក់ងារមានប្រភពចេញពីប្រទេសជប៉ុន ឆ្លងដែនទៅតំបន់អាស៊ីអាគ្នេយ៍។



ក្រុមហ៊ុនរបស់យើង Akatsuki គឺជាទីភ្នាក់ងារដែលផ្តល់ដំណោះស្រាយសម្រាប់ប្រតិបត្តិការអាជីវកម្មឆ្លងដែន ក្នុងទីផ្សារអាស៊ីអាគ្នេយ៍ដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សក្នុងប្រទេសនិមួយៗ ដោយផ្តល់ជូននូវបច្ចេកវិទ្យាដ៏ល្អឥតខ្ចោះរបស់ប្រទេសជប៉ុន។

លើសពីភ្នាក់ងារ យើងក៏មានបំណងផ្តល់នូវបទពិសោធន៍អាជីវកម្មប្រកបដោយភាពច្នៃប្រឌិត និងdigital tools ដែលប្រកបដោយភាពឆ្លាតវៃ និងមានភាពងាយស្រួលក្នុងការប្រើប្រាស់។ ក្រុមហ៊ុន Akatsuki មានបទពិសោធន៍ជាង 25 ឆ្នាំក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗនៅក្នុងទីផ្សារជប៉ុន និងចិន ហើយកំពុងធ្វើការដើម្បីបង្កើតនូវដំណោះស្រាយបច្ចេកវិទ្យាប្រកបដោយវិចារណញ្ញាណ និងមានភាពឆ្លាតវៃដែលអាចឆ្លងហួសរបាំងវប្បធម៌ និងព្រំដែននៃប្រទេស។

Akatsuki






## ដើម្បីការពង្រីកបច្ចេកវិទ្យាហរិញ្ញវត្ថុ(Fintech)និងការទូទាត់ឆ្លងដែន

កម្ពុជាកំពុងរៀបចំយ៉ាងសកម្មនូវអនាគតនៃបច្ចេកវិទ្យាហិរញ្ញ(Fintech)និងសេវាកម្មហិរញ្ញវត្ថុឌីជីថល ជាមួយនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការបង្កើតថ្មី។ ការរៀបចំខ្លួនដ៏ល្អនេះ បានទាក់ទាញក្រុមហ៊ុន និងវិនិយោគិនអន្តរជាតិលើវិស័យ Fintech ជាច្រើនដែលកំពុងស្វែងរកការសហការគ្នាជាមួយនឹងឱកាសពិសេសនៅក្នុងទីផ្សារកម្ពុជា។ ក្រុមហ៊ុនAkatsuki ដែលមានភាពនាំមុខនៅក្នុងការវវិវត្តន៍នេះ បានចូលរួមក្នុងទីផ្សារមួយនេះដោយរលូននិងបានកំពុងកសាងយុទ្ធសាស្ត្រពាណិជ្ជកម្មអេឡិចត្រូនិកឆ្លងដែនដ៏ទំនើបមួយ។ បេសកកម្មរបស់យើងគឺមានភាពសាមញ្ញ ប៉ុន្តែនិងមានឥទ្ធិពលយ៉ាងធំធេង។ បេសកកម្មរបស់យើងគឺផ្តល់ជូនអាជីវកម្មជាច្រើន នូវកូនសោរគន្លឹះដើម្បីធ្វើអោយអាជីវកម្មឆ្លងដែននៅក្នុងតំបន់អាស៊ីអាគ្នេយ៍កាន់តែមានសក្តានុពល។ មិនថាលោកអ្នកជាអាជីវកម្មទើបតែបង្កើតថ្មីក្នុងស្រុក ឬក៏ជាក្រុមហ៊ុនលំដាប់ពិភពលោកដ៏ល្បីនោះទេ ដំណោះស្រាយបច្ចេកវិទ្យារបស់យើងដែលបានរចនាឡើងអាចបត់បែនតាមតម្រូវការរបស់លោកអ្នក នឹងនាំលោកអ្នកចូលទៅក្នុងពាណិជ្ជកម្មឆ្លងដែនដ៏មានភាពស្មុគស្មាញនេះបានដោយរលូននិងមានទំនុកចិត្ត។

## ការអភិវឌ្ឍន៍គេហទំព័រនិងអាជីវកម្មEC

ជាមួយនឹងភាពប៉ិនប្រសប់ជាង 20 ឆ្នាំក្នុងការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យានៅក្នុងទីផ្សារប្រទេសជប៉ុន និងប្រទេសចិន យើងនឹងផ្តល់នូវបទពិសោធន៍ឌីជីថលដែលលើសពីការរំពឹងទុករបស់លោកអ្នក។ យុទ្ធសាស្ត្រE-commerc របស់ Akatsuki គឺខិតខំប្រែងប្រែងនាំមកនូវភាពជោគជ័យទៅដល់ការដឹកនាំអាជីវកម្មរបស់លោកអ្នក ចាប់ពីការចាប់ផ្តើមអាជីវកម្មថ្មី រហូតដល់ការធ្វើឌីជីថលភាវូបនីយកម្មទៅលើអាជីវកម្មដែលមានស្រាប់ក្នុងទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកអាស៊ីអាគ្នេយ៍មិនថាជាអាជីវកម្មខ្នាតតូចឬអាជីវកម្មខ្នាតធំឡើយ ។យុទ្ធសាស្ត្ររបស់ Akatsuki គឺផ្តោតលើចំនុចសំខាន់ពីរ។ 1) ធ្វើអោយភាពស្មុគស្មាញនៃអាជីវកម្មឆ្លងដែនមានភាពសាមញ្ញ និង 2) ការបង្កើតអោយមានទំនាក់ទំនងគ្នារវាងទីផ្សារចម្រុះ។

## Fintechនិងការទូទាត់

បច្ចេកវិទ្យាហិរិញ្ញវត្ថុ(FinTech )នៅតំបន់អាស៊ីអាគ្នេយ៍មានភាពចម្រុះ និងស្មុគស្មាញ ដូច្នេះវាត្រូវការចាំបាច់អោយមានការយល់ដឹងទូលំទូលាយនិងការរៀបចំទុកជាមុនសំរាប់អ្នកដែលចង់ធ្វើការស្វែងយល់ពីវិស័យនេះ។ ក្រុមហ៊ុនAkatsuki ផ្តល់នូវយុទ្ធសាស្ត្រដែលមានលក្ខណៈព្យាករទុកជាមុននិងសេវាកម្មប្រតិបត្តិការដែលអាចប្រើប្រាស់សមស្របជាមួយប្រព័ន្ធអេកូឡូស៊ី fintech ដែលកំពុងតែរីកចំរើនខ្លាំងរបស់ប្រទេសកម្ពុជា ។ យើងនឹងផ្តល់នូវដំណោះស្រាយបច្ចេកវិទ្យាដែលស្របតាមតម្រូវការវិវត្តរបស់អតិថិជន តាមរយៈការសម្រួលការទូទាត់ឆ្លងដែន និងការបង្កើនប្រសិទ្ធភាពការផ្ទេរប្រាក់ជាដើម។

## OEM/ODMដែលមានប្រសិទ្ធខ្ពស់

ក្រុមហ៊ុន katsuki ផ្តល់ជូននូវយុទ្ធសាស្ត្រ OEM/ODM ដ៏ពិសេសមួយ ដោយឈរលើបរិយាកាសអំណោយផលល្អនៃការធ្វើប្រតិបត្តិការអាជីវកម្មក្នុងប្រទេសកម្ពុជា និងអត្ថប្រយោជន៍ផលិតកម្មក្នុងប្រទេសចិន។ តាមរយៈការសហការជាមួយរោងចក្រ OEM/ODM នៅក្នុងប្រទេសចិន និងរួមបញ្ចូលគ្នានូវយុទ្ធសាស្ត្រពាណិជ្ជកម្មអេឡិចត្រូនិកដ៏ល្អពិសេសរបស់យើង លោកអ្នកនឹងអាចអភិវឌ្ឍផលិតផលមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ដែលក្រុមហ៊ុនផ្សេងទៀតមិចអាចធ្វើតាមបាន ការណ៍នេះនឹងនាំទៅដល់ការបង្កើតអាជីវកម្មថ្មី និងអាចអោយលោកអ្នកធ្វើការសាកល្បងទីផ្សារនៅក្នុងប្រទេសកម្ពុជាផងដែរ។

Akatsuki

# អាជីវកម្ម EC និងសមិទ្ធផល

ក្រុមហ៊ុនAkatsuki យើងបានចូលរួមសហការក្នុងអាជីវកម្ម e-commerce របស់អតិថិជនជាច្រើន ហើយបានផ្តល់មិនត្រឹមតែការរចនា UI និងការអភិវឌ្ឍន៍រទេះទិញទំនិញ(shopping cart) និងប្រព័ន្ធទូទាត់ដែលចាំបាច់សម្រាប់គេហទំព័រ e-commerce ប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់នូវចំណេះនិងបទពិសោធន៍ទាក់ទងនឹងបទប្បញ្ញត្តិចាំបាច់សម្រាប់ការធ្វើអាជីវកម្មតាមប្រព័ន្ធECឆ្លងដែនផងដែរ។

សមិទ្ធផលសំខាន់ៗ

- គេហទំព័រផ្លូវការរបស់ China Converse
- គេហទំព័រផ្លូវការរបស់ Herschel China
- កម្មវិធីខ្នាតតូចរបស់Isetan Wechat




គេហទំព័រផ្លូវការរបស់ China Converse
(https://www.converse.com.cn/)

Akatsuki

## កម្មវិធីទូទាត់ និងសមិទ្ធផល

ក្រុមហ៊ុនAkatsuki បានបង្កើត និងផ្តល់ជូននូវប្រព័ន្ធទូទាត់មួយរួចមកហើយ បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិករទូទាត់ប្រាក់ពីធនាគារអាមេរិក។ បច្ចុប្បន្នយើងកំពុងរៀបចំផែនការដើម្បីទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិករទូទាត់ប្រាក់ថ្មីពីធនាគារក្នុងប្រទេសកម្ពុជាដោយប្រើប្រព័ន្ធទូទាត់មួយនេះដែរ។



Akatsuki

## OEM/ODM និងសមិទ្ធផល

ក្នុងចំណោម ក្រុមហ៊ុនOEM/ODM ជាច្រើននៅក្នុងប្រទេសចិន មកដល់ពេលនេះក្រុមហ៊ុនAkatsuki ធ្វើការជាមួយក្រុមហ៊ុនផលិតដែលអាចជានានូវគុណភាព និងអាចនិយាយចរចាគ្នាពីតំលៃផលិត ដើម្បីអភិវឌ្ឍន៍ផលិតផលផ្សេងៗជាច្រើនសំរាប់សហគ្រិនដែលទើបតែចាប់ផ្ដើម និងអភិវឌ្ឍន៍ផលិតផលថ្មីៗសំរាប់សហគ្រិនដែលមានស្រាប់ផងដែរ។

ប្រភេទផលិតផលសំខាន់ៗដែលយើងអាចធ្វើOEM/ODM

- ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ (ទូរទឹកកក ម៉ាស៊ីនសម្ងួតសក់ ទូរទស្សន៍។ល។)
- គ្រឿងសំអាង (សាប៊ូកក់សក់ ផលិតផលថែរក្សាស្បែក។ល។)
- ឧបករណ៍ (ថេប្លេត នាឡិកាឆ្លាតវៃ។ល។)



ថេប្លេតរបស់ក្រុមហ៊ុនstart up bloo vision (https://bloo.vision/)

# Akatsuki

# Contact Us



## Powered By AIMS

Akatsuki គឺជាក្រុមហ៊ុនអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យា(system development company)ដែលត្រូវបានបង្កើតឡើងដោយការវិនិយោគពី AIMS មានទីស្នាក់ការកណ្ដាលនៅទីក្រុងតូក្យូដាយមុង។ ដោយផ្អែកលើបទពិសោធន៍ជាង 20 ឆ្នាំក្នុងអាជីវកម្មឆ្លងដែនរវាងជប៉ុន និងចិន យើងក៏បានចាប់ផ្ដើមអាជីវកម្មនេះនៅក្នុងប្រទេសកម្ពុជាដែរដើម្បីចាប់យកឱកាសអាជីវកម្មឆ្លងដែនរវាងប្រទេសចិន និងកម្ពុជា។


### Location Address

#159, 4th floor, St 113,
Sangkat Boeung Keng Kang 3,
Khan Chamkarmon, Phnom Penh

### Email Address

info@akatsukiplan.com.kh

### Website

https://ai-ms.co.jp/
https://akatsukiplan.com.kh/


សូមអរគុណ